ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ...៤៤៣ សជណ/គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី០៦... ខែកញ្ញា ឆ្នាំ២០១៣

**គោរពជូន**
**ឯកឧត្តមអភិបាលខេត្តបាត់ដំបង កំពង់ស្ពឺ កំពង់ធំ**
**មណ្ឌលគិរី ព្រៃវែង រតនគិរី សៀមរាប ព្រះសីហនុ ស្ទឹងត្រែង**
**ស្វាយរៀង និងខេត្តឧត្តរមានជ័យ**

**កម្មវត្ថុ** ៖ ជំរុញការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ផ្នែកសេវាសង្គមដែលគាំទ្រដោយកម្មវិធីសិទ្ធិកុមារ នៃអង្គការយូនីសេហ្វ។

**យោង** ៖
- សេចក្តីណែនាំលេខ២៩៥ សជណ/គ.ជ.អ.ប ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១១ របស់លេខាធិការដ្ឋាន គ.ជ.អ.ប ស្តីពីការរៀបចំអនុវត្តកម្មវិធីសិទ្ធិកុមារដែលគាំទ្រដោយអង្គការយូនីសេហ្វ។
- សេចក្តីណែនាំលេខ៤០២ សជណ/គ.ជ.អ.ប ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ របស់លេខាធិការដ្ឋាន គ.ជ.អ.ប ស្តីពីការរៀបចំមន្ត្រីបន្ថែមសម្រាប់ទទួលបន្ទុកផ្នែកសេវាសង្គមនៅថ្នាក់ក្រោមជាតិ។
- សេចក្តីណែនាំលេខ២០២ សជណ/គ.ជ.អ.ប ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ របស់លេខាធិការដ្ឋាន គ.ជ.អ.ប ស្តីពីក្របខ័ណ្ឌសកម្មភាពសេវាសង្គមនៅថ្នាក់ក្រោមជាតិ ។
- របាយការណ៍ចុះតាមដានរបស់ក្រុមការងារលេខាធិការដ្ឋាន គ.ជ.អ.ប។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមជ្រាបថា កន្លងមកក្រុមការងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប បានជ្រើសរើសខេត្តគោលដៅដែលអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ផ្នែកសេវាសង្គម គាំទ្រដោយកម្មវិធីសិទ្ធិកុមារនៃអង្គការយូនីសេហ្វមួយចំនួនដើម្បីចុះតាមដាន និងត្រួតពិនិត្យ។ ក្រុមការងារបានរកឃើញបញ្ហាប្រឈមមួយចំនួន ដែលធ្វើឲ្យការអនុវត្តសកម្មភាព និងការទូទាត់ថវិកាគម្រោងនៅមានភាពយឺតយ៉ាវ។ ដើម្បីធានាឲ្យការអនុវត្តគម្រោងនេះប្រព្រឹត្តទៅកាន់តែល្អប្រសើរ លេខាធិការដ្ឋាន គ.ជ.អ.ប សូមធ្វើការណែនាំដូចខាងក្រោម៖

- ធានាឲ្យមានការរៀបចំផែនការសកម្មភាព និងថវិកា និងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ផ្នែកសេវាសង្គមដោយពង្រឹងការតាមដាន គាំទ្រ ដោយទីប្រឹក្សាស្រុក និងមន្ត្រីសេវាសង្គមស្រុក។

មហាវិថីព្រះនរោត្តមៈ លេខាធិការដ្ឋាននៃគ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទ : (៨៥៥-២៣) ៧២០ ០៦១ / ៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh
Norodom Blvd., National Committee for Sub-National Democratic Development Secretariat (NCDDS). Ministry of Interior. Tel: (855-23) 720 061 / 720 038

- សម្របសម្រួលជាមួយធនាគារខេត្ត ដើម្បីធានានូវការទូទាត់មូលនិធិឃុំ សង្កាត់ ផ្នែកសេវាសង្គម ដែលគាំទ្រដោយអង្គការយូនីសេហ្វឲ្យបានទាន់ពេលវេលា។
- ពង្រឹងការគាំទ្ររបស់ទីប្រឹក្សាស្រុក មន្ត្រីសេវាសង្គមស្រុក ក៏ដូចជាទីប្រឹក្សាខេត្ត មន្ត្រីសេវាសង្គមខេត្ត និងអ្នកពាក់ព័ន្ធផ្សេងទៀតទៅដល់ឃុំ សង្កាត់ តាមរយៈការចុះតាមដាន និងគាំទ្រជាប្រចាំដល់មូលដ្ឋាន។
- ពង្រឹងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តមូលនិធិឃុំ សង្កាត់ ផ្នែកសេវាសង្គមស្របតាមសូចនាករដែលបានកំនត់ និងផ្ញើជូនលេខាធិការដ្ឋាន គ.ជ.អ.ប ឲ្យបានទាន់ពេលវេលា។
- រាល់បញ្ហាប្រឈមនានាក្នុងការរៀបចំផែនការសកម្មភាព ការអនុវត្ត និងការទូទាត់ថវិកាផ្នែកសេវាសង្គម ដែលគាំទ្រដោយអង្គការយូនីសេហ្វ ដែលថ្នាក់ខេត្តមិនអាចសម្របសម្រួលបានថ្នាក់ខេត្តត្រូវរាយការណ៍ជាបន្ទាន់មកលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីសម្របសម្រួល និងដោះ ស្រាយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តារៀបចំ ចាត់ចែង និងអនុវត្តការងារនេះឲ្យទទួលបានប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

ជ. ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប
អនុប្រធាន

ចាន់ ថារីឆ

**ចម្លងជូន៖**

-ក្រសួងមហាផ្ទៃ (ក្រុមការងារគ្រប់គ្រងអនុកម្មវិធីទី២)
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក្រុមការងារគ្រប់គ្រងអនុកម្មវិធីទី៤)
-អគ្គនាយកដ្ឋានធនាគារជាតិ
-ធនាគាររាជធានី ខេត្ត
-ក្រុមប្រឹក្សាខេត្តគោលដៅ
-គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
-អង្គការយូនីសេហ្វ
-អង្គការយូនីអេហ្វភីអេ
-ឯកសារ-កាលប្បវត្តិ